# សាកលវិទ្យាល័យប៊ៀលប្រាយ
# BUILD BRIGHT UNIVERSITY

**សំណើគម្រោងស្រាវជ្រាវសារណាបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ**
**ដាក់ជូនសាខាសាកលវិទ្យាល័យប៊ៀលប្រាយ ខេត្តសៀមរាប**

**មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**
**ជំនាញបច្ចេកវិទ្យាព័ត៌មាន**

**ប្រធានបទស្តីអំពី**

## ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ
## នៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application


**រៀបរៀងដោយក្រុមនិស្សិតជំនាន់ទី២២៖**

១-និស្សិត **ខុធ ពិសិទ្ធិ**
២-និស្សិត **លីម សាប្រិយ៍**
៣-និស្សិត **ហួរ សីហា**
៤-និស្សិត **សាន ពិសិដ្ឋ**
៥-និស្សិត **រើន ណារុំ**
៦-និស្សិត **កែវ ភារ**

**សាស្ត្រាចារ្យណែនាំ: ឡោ សូត្រ**


**យោបល់សាស្ត្រាចារ្យណែនាំ:** ..........................................................................

......................................................................................................................

ថ្ងៃចន្ទ ៩កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ខេត្តសៀមរាប ថ្ងៃទី........ខែ................ឆ្នាំ២០២៦
ហត្ថលេខា

## ១. សេចក្តីផ្តើម( ខុធ ពិសិទ្ធិ )

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាបានអនុវត្ត យុទ្ធសាស្ត្របញ្ចកោណ ដែលជាគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់រាជរដ្ឋាភិបាល ដោយឈរលើមូលដ្ឋាននៃស្ថិរភាពនយោបាយ សន្តិភាព សន្តិសុខ បច្ចេកវិទ្យា និងការអភិវឌ្ឍប្រកបដោយចីរភាព។ កំណើននៃវិស័យពាណិជ្ជកម្ម អាជីវកម្មលក់រាយ និងសហគ្រាសធុនតូច និងមធ្យម (SMEs) បានបង្កើនតម្រូវការក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីគ្រប់គ្រងប្រតិបត្តិការអាជីវកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តដល់ការអនុវត្តបច្ចេកវិទ្យាឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ក្នុងវិស័យសាធារណៈ និងឯកជន ដើម្បីបង្កើនផលិតភាព កាត់បន្ថយការងារធ្វើដោយដៃ និងលើកកម្ពស់ការប្រកួតប្រជែងរបស់អាជីវកម្មនៅក្នុងសម័យឌីជីថល។

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application" មានគោលបំណងសិក្សាពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសារពើភ័ណ្ឌ។ មូលហេតុដែលជំរុញឱ្យជ្រើសរើសប្រធានបទនេះ គឺដោយសារការគ្រប់គ្រងស្តុកទំនិញដោយវិធីបែបប្រពៃណីនៅតែជួបបញ្ហាដូចជា ការកត់ត្រាទិន្នន័យមិនទាន់មានភាពត្រឹមត្រូវ ការតាមដានស្តុកមានភាពយឺតយ៉ាវ និងពិបាកក្នុងការត្រួតពិនិត្យទំនិញចេញចូល។ Mobile Application អាចជួយគ្រប់គ្រងព័ត៌មានសារពើភ័ណ្ឌបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង កាត់បន្ថយកំហុស បង្កើនល្បឿនការងារ និងជួយឱ្យការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងមានភាពត្រឹមត្រូវជាងមុន។ លើសពីនេះ បច្ចេកវិទ្យាបណ្តាញកុំព្យូទ័រ និងប្រព័ន្ធព័ត៌មានបានដើរតួនាទីសំខាន់ក្នុងការផ្ទុក ចែករំលែក និងគ្រប់គ្រងទិន្នន័យរវាងអ្នកប្រើប្រាស់ និងអង្គភាពប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ទីទីម៉ាត២៥០០ គឺជាអាជីវកម្មលក់រាយដែលផ្តល់ជូននូវទំនិញប្រើប្រាស់ប្រចាំថ្ងៃជាច្រើនប្រភេទ ដូចជា គ្រឿងឧបភោគបរិភោគ គ្រឿងសម្អាង និងសម្ភារៈប្រើប្រាស់ផ្សេងៗ ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ អង្គភាពនេះមានការគ្រប់គ្រងផ្នែកទិញ ផ្នែកលក់ ផ្នែកស្តុក និងផ្នែកគ្រប់គ្រងទូទៅ ដែលទាមទារការគ្រប់គ្រងទិន្នន័យឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ បច្ចុប្បន្ន អង្គភាពមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាណាមួយសម្រាប់គ្រប់គ្រងការលក់ និងការគ្រប់គ្រងទិន្នន័យស្តុកនៅឡើយទេ។ ការគ្រប់គ្រងសារពើភ័ណ្ឌតាមរយៈ Mobile Application នៅតែមានសក្តានុពលក្នុងការអភិវឌ្ឍបន្ថែមនៅការគ្រប់គ្រងដែលមានស្រាប់។ ប្រព័ន្ធនេះអាចជួយតាមដានស្តុកទំនិញ កត់ត្រាការនាំចូល និងការលក់ ចេញរបាយការណ៍ និងជូនដំណឹងនៅពេលស្តុកជិតអស់ ដែលជួយបង្កើនប្រសិទ្ធភាពការងារ និងគាំទ្រការអភិវឌ្ឍអាជីវកម្មឱ្យកាន់តែទំនើប។

## ២. ចំណោទបញ្ហា

តាមរយៈការសិក្សាលើប្រធានបទ «ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត ២៥០០ តាមរយៈ Mobile Application» បានរកឃើញថា ការគ្រប់គ្រងសារពើភ័ណ្ឌនៅតែជួបប្រទះបញ្ហាមួយចំនួន ដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាកម្ម។ បញ្ហាសំខាន់ៗដែលអាចដោះស្រាយបានមានដូចខាងក្រោម៖

- ការគ្រប់គ្រងស្តុកមិនទាន់មានភាពត្រឹមត្រូវ ដោយសារការកត់ត្រាទិន្នន័យដោយដៃ ឬប្រើប្រាស់ប្រព័ន្ធដែលមិនទាន់ភ្ជាប់ទិន្នន័យជាមួយគ្នា បណ្តាលឱ្យមានភាពខុសគ្នារវាងស្តុកជាក់ស្តែង និងទិន្នន័យក្នុងប្រព័ន្ធ។
- ពិបាកក្នុងការតាមដានចលនាទំនិញ (Stock In/Stock Out) ដែលធ្វើឱ្យអ្នកគ្រប់គ្រងមិនអាចពិនិត្យព័ត៌មានស្តុកបានភ្លាមៗ និងអាចបណ្តាលឱ្យទំនិញខ្វះ ឬលើសតម្រូវការ។
- ការរៀបចំរបាយការណ៍ចំណាយពេលយូរ ដោយសារទិន្នន័យត្រូវប្រមូលពីប្រភពផ្សេងៗ និងធ្វើការគណនាដោយដៃ ដែលអាចបង្កឱ្យមានកំហុស និងប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង។
- មិនអាចគ្រប់គ្រង និងត្រួតពិនិត្យសារពើភ័ណ្ឌតាមរយៈទូរស័ព្ទដៃបានគ្រប់ពេលវេលា ដែលធ្វើឱ្យអ្នកគ្រប់គ្រងត្រូវស្ថិតនៅទីតាំងការងារ ដើម្បីពិនិត្យទិន្នន័យ និងមិនមានភាពងាយស្រួលក្នុងការតាមដានប្រតិបត្តិការពេលនៅក្រៅអង្គភាព។

## ៣. គោលបំណងនៃការស្រាវជ្រាវ( លឹម សារុប្រិយ៍ )

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application ដើម្បីសម្រួល និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្តុកទំនិញ។ ជាក់ស្តែង ការស្រាវជ្រាវមានគោលបំណងជួយឱ្យការគ្រប់គ្រង និងតាមដានបរិមាណស្តុកទំនិញមានភាពត្រឹមត្រូវ និងទាន់ពេលវេលា ព្រមទាំងអាចតាមដានការនាំចូល ការលក់ និងចលនាទំនិញ (Stock In/Stock Out) បានយ៉ាងងាយស្រួល។

ដំណោះស្រាយសម្រាប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ ដូចជា៖

- ការធ្វើស្វ័យប្រវត្តកម្មស្តុក
  - ជំនួសការកត់ត្រាទិន្នន័យដោយដៃ ដោយប្រើប្រាស់មុខងារ Barcode / QR Code Scanner ភ្ជាប់ជាមួយ Mobile Application។
  - រាល់ពេលមានការទិញ ចូល ឬលក់ចេញ ទិន្នន័យស្តុកជាក់ស្តែងនឹងត្រូវធ្វើបច្ចុប្បន្នភាព (Update) ដោយស្វ័យប្រវត្តិ និងភ្លាមៗទៅកាន់ប្រព័ន្ធមូលដ្ឋាន

ទិន្នន័យ (Database) ដែលកាត់បន្ថយភាពខុសគ្នារវាងស្តុកជាក់ស្តែង និងស្តុកក្នុងប្រព័ន្ធបានស្ទើរតែ ១០០%។

- ប្រព័ន្ធតាមដានចលនាទំនិញទាន់ពេលវេលា
  - បង្កើត Dashboard សម្រាប់តាមដានចលនាទំនិញ លើ Mobile App ជាមួយមុខងារ Smart Notification System។
  - អ្នកគ្រប់គ្រងអាចពិនិត្យមើលចលនាទំនិញបានភ្លាមៗ ព្រមទាំងទទួលបានការជូនដំណឹងជាមុននៅពេលទំនិញជិតអស់ពីស្តុក ឬទំនិញជិតផុតកំណត់ ដែលជួយការពារបញ្ហាខ្វះ ឬលើសទំនិញក្នុងស្តុក។
- ការបង្កើតរបាយការណ៍ស្វ័យប្រវត្តិ
  - បញ្ចូលមុខងារ Automated Report Generator នៅក្នុងប្រព័ន្ធ ដើម្បីប្រមូលផ្តុំ និងគណនាទិន្នន័យចំណូល ចំណាយ ចលនាលក់ និងទិន្នន័យសារពើភ័ណ្ឌដោយស្វ័យប្រវត្តិ។
  - កាត់បន្ថយពេលវេលាក្នុងការរៀបចំរបាយការណ៍ និងលុបបំបាត់កំហុសឆ្គងពីការគណនាដោយដៃ។ អ្នកគ្រប់គ្រងអាចទាញយករបាយការណ៍ប្រចាំថ្ងៃ សប្តាហ៍ ឬខែ បានភ្លាមៗ ដើម្បីជួយដល់ការសម្រេចចិត្តបែបយុទ្ធសាស្ត្របានត្រឹមត្រូវ និងទាន់ពេលវេលា។
- ការគ្រប់គ្រងពីចម្ងាយតាមរយៈទូរស័ព្ទដៃ
  - អភិវឌ្ឍប្រព័ន្ធ Mobile Application ផ្អែកលើបច្ចេកវិទ្យា Cloud Database ដែលមានកម្រិតសុវត្ថិភាពខ្ពស់ និងការបែងចែកសិទ្ធិប្រើប្រាស់។
  - អ្នកគ្រប់គ្រងមិនចាំបាច់នៅទីតាំងផ្ទាល់នោះទេ គឺអាចចូលត្រួតពិនិត្យគ្រប់គ្រង និងតាមដានប្រតិបត្តិការសារពើភ័ណ្ឌទាំងមូលបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់ទូរស័ព្ទដៃដែលមានអ៊ីនធឺណិត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើការបង្កើត ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត ២៥០០ តាមរយៈ Mobile Application ដែលមានដែនកំណត់ដូចខាងក្រោម៖

ប្រព័ន្ធដែលត្រូវបង្កើតរួមមាន៖

- បង្កើត Mobile Application សម្រាប់អ្នកប្រើប្រាស់ចូលប្រើប្រព័ន្ធ។
- រចនាមូលដ្ឋានទិន្នន័យ (Database) សម្រាប់រក្សាទុកព័ត៌មានសារពើភ័ណ្ឌ។
- បង្កើតទម្រង់ Login សម្រាប់អ្នកគ្រប់គ្រង និងបុគ្គលិក។
- បង្កើតមុខងារគ្រប់គ្រងអ្នកប្រើប្រាស់ ។
- បង្កើតមុខងារគ្រប់គ្រងប្រភេទទំនិញ ។

- បង្កើតមុខងារគ្រប់គ្រងទំនិញ។
- បង្កើតមុខងារគ្រប់គ្រងអ្នកផ្គត់ផ្គង់។
- បង្កើតមុខងារគ្រប់គ្រងការនាំចូលទំនិញ។
- បង្កើតមុខងារគ្រប់គ្រងការលក់ទំនិញ។
- បង្កើតមុខងារគ្រប់គ្រងស្តុកទំនិញ និងចលនាទំនិញ។
- បង្កើតរបាយការណ៍ស្តុកទំនិញ ការនាំចូល និងការលក់។
- រចនា Prototype (UX/UI) សម្រាប់ Mobile Application ដូចជា៖
    - Splash Screen
    - Login Screen
    - Dashboard
    - Product Screen
    - Category Screen
    - Supplier Screen
    - Purchase Screen
    - Sales Screen
    - Stock Movement Screen
    - User Profile Screen

**បច្ចេកវិទ្យាដែលប្រើប្រាស់៖**

- Flutter Framework សម្រាប់អភិវឌ្ឍ Mobile Application (Front-end)។
- MySQL Server សម្រាប់គ្រប់គ្រងមូលដ្ឋានទិន្នន័យ។
- Visual Studio Code សម្រាប់ការអភិវឌ្ឍកម្មវិធី។

# ៥. វិធីសាស្ត្រស្រាវជ្រាវ ( ហួរ សីហា )

## ៥.១. ការជ្រើសរើសគំរូតាង

### ៥.១.១. ទំហំនៃគំរូតាង

ក្នុងការកំណត់ទំហំគំរូតាងសម្រាប់ការស្រាវជ្រាវលើប្រធានបទ «ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application» ក្រុមយើងខ្ញុំបានជ្រើសរើសទំហំគំរូ សរុបចំនួន ៣ នាក់ ដើម្បីធ្វើការប្រមូលទិន្នន័យ។

### ៥.១.២. បច្ចេកទេសនៃការជ្រើសរើសគំរូតាង

ក្នុងការស្រាវជ្រាវលើប្រធានបទ «ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application» ក្រុមយើងខ្ញុំបានជ្រើសរើស ការជ្រើសរើសគំរូតាមបច្ចេកទេសមិនចៃដន្យ ដោយជ្រើសរើសអ្នកដែលមានចំណេះដឹង បទពិសោធន៍ និងការ

ទទួលខុសត្រូវដោយផ្ទាល់លើការគ្រប់គ្រងសារពើភ័ណ្ឌ និងប្រតិបត្តិការរបស់ហាង ដើម្បីផ្តល់ព័ត៌មានដែលមានភាពត្រឹមត្រូវ និងគួរឱ្យទុកចិត្តសម្រាប់ការសិក្សាស្រាវជ្រាវ។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវរួមមាន៖

- ម្ចាស់ហាង ចំនួន ១ នាក់
- អ្នកគ្រប់គ្រងសារពើភ័ណ្ឌ ចំនួន ២ នាក់

សរុបអ្នកផ្តល់ព័ត៌មានសម្រាប់ការស្រាវជ្រាវមានចំនួន ៣ នាក់។ ការជ្រើសរើសអ្នកទាំងនេះគឺដោយសារពួកគេមានចំណេះដឹង និងបទពិសោធន៍ផ្ទាល់ក្នុងការគ្រប់គ្រងស្តុកទំនិញ ការនាំចូលទំនិញ ការត្រួតពិនិត្យបរិមាណស្តុក និងការរៀបចំរបាយការណ៍។ ដូច្នេះ ព័ត៌មានដែលទទួលបានពីអ្នកទាំងនេះមានភាពសមស្រប និងអាចប្រើប្រាស់សម្រាប់វិភាគតម្រូវការ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌតាមរយៈ Mobile Application បានយ៉ាងមានប្រសិទ្ធភាព។

## ៥.២. ប្រភេទទិន្នន័យ និងបច្ចេកទេសប្រមូលទិន្នន័យ( រើន ណារុំ)

### ៥.២.១. ប្រភេទទិន្នន័យ

#### ៥.២.១.១. ទិន្នន័យចម្បង

ក្នុងការសិក្សាស្រាវជ្រាវនេះ ការប្រមូលទិន្នន័យចម្បងត្រូវបានប្រមូលដោយផ្ទាល់ពីហាងទីទីម៉ាត២៥០០ ដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍ និងការសង្កេតផ្ទាល់ ដើម្បីទទួលបានព័ត៌មានដែលមានភាពពាក់ព័ន្ធ និងឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃដំណើរការគ្រប់គ្រងសារពើភ័ណ្ឌ។ ការសម្ភាសន៍ត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់អំពីតម្រូវការ បញ្ហាប្រឈម និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធ ខណៈការសង្កេតផ្ទាល់ត្រូវបានអនុវត្ត ដើម្បីសិក្សាអំពីលំហូរការងារនិងដំណើរការប្រតិបត្តិការដែលកំពុងអនុវត្តជាក់ស្តែង។

ព័ត៌មានដែលទទួលបានពីការប្រមូលទិន្នន័យរួមមាន ប្រវត្តិ និងព័ត៌មានទូទៅរបស់ទីទីម៉ាត២៥០០ រចនាសម្ព័ន្ធការងារ និងតួនាទីរបស់បុគ្គលិក ដំណើរការគ្រប់គ្រងស្តុកទំនិញបច្ចុប្បន្ន ដំណើរការនាំចូលទំនិញ (Purchase) ដំណើរការលក់ទំនិញ (Sales) និងដំណើរការគ្រប់គ្រងអ្នកផ្គត់ផ្គង់ (Supplier)។ លើសពីនេះ ការសិក្សាក៏ផ្តោតលើវិធីសាស្ត្រកត់ត្រា និងគ្រប់គ្រងព័ត៌មានផលិតផល និងបរិមាណស្តុក ព្រមទាំងកំណត់បញ្ហា និងឧបសគ្គដែលកើតមានក្នុងការគ្រប់គ្រងសារពើភ័ណ្ឌនាពេលបច្ចុប្បន្ន។

ជាមួយគ្នានេះ ក្រុមស្រាវជ្រាវបានសិក្សាអំពី តម្រូវការរបស់អ្នកប្រើប្រាស់ចំពោះ Mobile Application និងតម្រូវការពាក់ព័ន្ធនឹងការរៀបចំ និងបង្ហាញរបាយការណ៍ស្តុកទំនិញ ការលក់ និងការនាំចូល។ ទិន្នន័យដែលប្រមូលបានត្រូវបានរៀបចំ ចាត់ថ្នាក់ និងវិភាគ ដើម្បីកំណត់តម្រូវការប្រព័ន្ធ និងមុខងារចាំបាច់សម្រាប់ជាមូលដ្ឋានក្នុងការរចនា និងអភិវឌ្ឍ

ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌនៅទីទីម៉ាត២៥០០ តាមរយៈ Mobile Application ឱ្យស្រប តាមតម្រូវការ និងស្ថានភាពជាក់ស្តែង។

### ៥.២.១.២. ទិន្នន័យមានស្រាប់(ភែខ ភារ)

ក្នុងការសិក្សាស្រាវជ្រាវនេះ ទិន្នន័យបន្ទាប់បន្សំត្រូវបានប្រមូលពីប្រភពឯកសារដែលមានស្រាប់ និងមានភាពពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ រួមមាន សៀវភៅ សារណា និងនិក្ខេបបទស្រាវជ្រាវ អត្ថបទវិទ្យាសាស្ត្រ ឯកសារបច្ចេកទេស ព្រមទាំងប្រភពព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត។ ការសិក្សាប្រភពឯកសារទាំងនេះមានគោលបំណងស្វែងយល់អំពីទ្រឹស្តី គោលការណ៍ បច្ចេកវិទ្យា និងវិធីសាស្ត្រដែលពាក់ព័ន្ធ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវិភាគ រចនា និងអភិវឌ្ឍប្រព័ន្ធ។

ខ្លឹមសារសំខាន់ៗដែលបានសិក្សា រួមមាន គោលគំនិត និងនិយមន័យ ប្រព័ន្ធព័ត៌មាន និង ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ ព្រមទាំងគោលការណ៍ និងវិធីសាស្ត្រដែលពាក់ព័ន្ធនឹងការគ្រប់គ្រងស្តុកទំនិញ។ លើសពីនេះ ការសិក្សាក៏បានផ្តោតលើ Mobile Application និងការអនុវត្តបច្ចេកវិទ្យាទូរស័ព្ទក្នុងវិស័យអាជីវកម្ម ដើម្បីស្វែងយល់ពីសក្តានុពល និងភាពសមស្របរបស់វាសម្រាប់ការគ្រប់គ្រងសារពើភ័ណ្ឌ។

### ៥.២.២. បច្ចេកទេសប្រមូលទិន្នន័យ

ចំពោះទិន្នន័យចម្បង ក្រុមយើងខ្ញុំបានប្រើប្រាស់បច្ចេកទេសក្នុងការ សម្ភាសន៍ និង ការសង្កេត ដោយធ្វើការសម្ភាសន៍ផ្ទាល់ជាមួយម្ចាស់ហាង និងអ្នកគ្រប់គ្រងសារពើភ័ណ្ឌ ព្រមទាំងសង្កេតដំណើរការគ្រប់គ្រងស្តុកទំនិញ និងការលក់ជាក់ស្តែង ដើម្បីប្រមូលព័ត៌មានដែលត្រឹមត្រូវ និងស្របតាមស្ថានភាពអាជីវកម្ម។

ចំពោះទិន្នន័យមានស្រាប់ ក្រុមយើងខ្ញុំបានប្រើប្រាស់បច្ចេកទេស ដកស្រង់ សង្ខេប និងបរប្រយោគ ពីសៀវភៅ សារណាស្រាវជ្រាវ អត្ថបទវិទ្យាសាស្ត្រ និងប្រភពអ៊ីនធឺណិត ដែលអាចទុកចិត្តបាន ដើម្បីធ្វើជាមូលដ្ឋានសម្រាប់រំលឹកទ្រឹស្តី និងការរចនាប្រព័ន្ធ។

## ៥.៣. បច្ចេកទេសវិភាគទិន្នន័យ(សាន ពិសិដ្ឋ)

ការស្រាវជ្រាវនេះប្រើប្រាស់ ការវិភាគបែបគុណវិស័យ ដោយធ្វើការរៀបចំទិន្នន័យតាមប្រភេទ និងវិភាគព័ត៌មានដែលប្រមូលបានពីការសម្ភាសន៍ និងការសង្កេត។

ការវិភាគត្រូវបានបែងចែកជា ២ ផ្នែក៖

- ការវិភាគបញ្ហាប្រព័ន្ធបច្ចុប្បន្ន
  - វិភាគបញ្ហានៃការគ្រប់គ្រងស្តុកដោយដៃ
  - វិភាគការគ្រប់គ្រងទិន្នន័យមិនទាន់មានប្រសិទ្ធភាព
  - វិភាគភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍
  - វិភាគបញ្ហាក្នុងការតាមដានស្តុកទំនិញ

- ការវិភាគតម្រូវការប្រព័ន្ធថ្មី
  - Functional Requirements
  - Login
  - Dashboard
  - User Management
  - Category Management
  - Product Management
  - Supplier Management
  - Purchase Management
  - Sales Management
  - Non-Functional Requirements
  - ប្រព័ន្ធមានភាពងាយស្រួលប្រើប្រាស់ (User Friendly)
  - មានសុវត្ថិភាពក្នុងការផ្ទុកទិន្នន័យ
  - ដំណើរការបានលឿន
  - អាចប្រើប្រាស់តាម Mobile Application បានគ្រប់ពេលវេលា
  - មានភាពត្រឹមត្រូវ និងអាចពង្រីកប្រព័ន្ធនាពេលអនាគត

## ៦. ពន្យល់ពាក្យគន្លឹះ

-ពាក្យ **ប្រព័ន្ធព័ត៌មាន** (**Information System**) សំដៅដល់ប្រព័ន្ធដែលប្រើសម្រាប់ប្រមូល រក្សាទុក គ្រប់គ្រង និងបង្ហាញទិន្នន័យ ដើម្បីគាំទ្រការសម្រេចចិត្តរបស់អង្គភាព។

-ពាក្យ **សារពើភ័ណ្ឌ** (**Inventory**) សំដៅដល់ទំនិញ ឬសម្ភារៈដែលអាជីវកម្មរក្សាទុកសម្រាប់លក់ ឬប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្ម។

-ពាក្យ **ប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ** សំដៅដល់ប្រព័ន្ធដែលគ្រប់គ្រងព័ត៌មានអំពីផលិតផល ការនាំចូល ការលក់ និងបរិមាណស្តុកទំនិញ។

-ពាក្យ Mobile Application សំដៅដល់កម្មវិធីដែលអភិវឌ្ឍសម្រាប់ដំណើរការលើស្មាតហ្វូន ឬថេប្លេត ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចប្រើប្រាស់ប្រព័ន្ធបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

-ពាក្យ Flutter សំដៅដល់ Framework របស់ Google ដែលប្រើសម្រាប់អភិវឌ្ឍ Mobile Application សម្រាប់ Android និង iOS ពីកូដតែមួយ។

-ពាក្យ MySQL Server សំដៅដល់ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ (DBMS) ដែលប្រើសម្រាប់រក្សាទុក និងគ្រប់គ្រងទិន្នន័យរបស់ប្រព័ន្ធ។

# ៧. ផែនការសកម្មភាព

| | | តារាងផែនការអនុវត្តការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មិថុនា | | | | កក្កដា | | | | សីហា | | | | កញ្ញា | | | | តុលា | | | | | វិច្ឆិកា | | | | ធ្នូ | | | | | មករា | | | | | |
| ល.រ | សកម្មភាព | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | 32 | 33 | 34 | 35 | 36 |
| 1 | បង្កើតគម្រោង និងរៀបចំផែនការការងារ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | សិក្សាពីប្រព័ន្ធបច្ចុប្បន្ន | | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | ប្រមូលព័ត៌មាន និងសិក្សាតម្រូវការរបស់ប្រព័ន្ធ | | | | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | វិភាគ និងរៀបចំតម្រូវការប្រព័ន្ធ | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | រចនាប្រព័ន្ធ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |
| 6 | រៀបចំទិន្នន័យ និងមូលដ្ឋានទិន្នន័យ | | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | | | | |
| 7 | បង្កើតប្រព័ន្ធ និងអភិវឌ្ឍកម្មវិធី | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | |
| 8 | តេស្តប្រព័ន្ធ និងកែសម្រួលបញ្ហា | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | |
| 9 | ប្រមូលលទ្ធផលសាកល្បង | | | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | | | | | | | |
| 10 | បញ្ចប់ការងារ និងប្រគល់ស្នាដៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | ■ |